# សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

## យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស

## នៃអង្គការសហប្រជាជាតិ

## បណ្តឹងលេខ ៤២៨/១៩៩០

CCPR/C/50/D/428/1990

**( សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ )**


បកប្រែដោយ៖ លោក ស្រ៊ាង ចិន្តា

កែសម្រួលដោយ ៖ មាស បូរ៉ា

រចនាដោយ៖ អែម ចន្ទី

# បណ្តឹងលេខ ៤២៨/១៩៩០

**ប្តឹងដោយ:** Yvonne M'Boissona នៅថ្ងៃ១៤ ខែវិច្ឆិកា ឆ្នាំ១៩៩០

**ជនរងគ្រោះត្រូវចោទប្រកាន់:** ប្អូនប្រុសដើមបណ្តឹងឈ្មោះ Francois Bozize

**រដ្ឋភាគី:** សាធារណរដ្ឋអាហ្វ្រិកកណ្តាល

**ប្រកាសអាចទទួលយកបាន:** ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩២

(សម័យប្រជុំទី៤៥)

**កាលបរិច្ឆេទអនុម័តសេចក្តីសម្រេច:** ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៤

(សម័យប្រជុំទី៥០)

**កម្មវត្ថុ:** ចោទពីការបដិសេធនូវសិទ្ធិរបស់គូរប្រជែងខាងនយោបាយ អំឡុងពេលនៃការចាប់ខ្លួននិងការឃុំខ្លួន ព្រមទាំងចោទពីការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមស្របមួយ

**បញ្ហានីតិវិធី:** ការបរាជ័យរបស់រដ្ឋភាគី ដើម្បីបញ្ជាក់ទៅលើភាពអាចទទួលយកបាននិងលើអង្គសេចក្តី (កង្វះភ័ស្តុតាង នៃការអះអាង)

**បញ្ហាសំខាន់:** សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌(ការធ្វើបាបនិងទារុណកម្ម) ប្រព្រឹត្តកម្ម អំឡុងពេលជាប់ពន្ធនាគារ (សេរីភាព និងសន្តិសុខជាមនុស្ស)

**មាត្រានៃកតិកាសញ្ញា:** មាត្រា៧, ៩, ១០, ១៤(១)(៣) និងមាត្រា១៩

**មាត្រានៃពិធីសារបន្ថែម:** មាត្រា៤(២) និងមាត្រា៥(២)(ខ)

**១.** ដើមបណ្តឹង នៃបណ្តឹងនេះ គឺ Yvonne M'Boissona ជាពលរដ្ឋ នៃសាធារណរដ្ឋអាហ្វ្រិកកណ្តាល រស់នៅតំបន់ Stains ប្រទេសបារាំង។ នាងដាក់ពាក្យប្តឹងក្នុងនាមប្អូនប្រុសរបស់ខ្លួន ឈ្មោះ Francois Bozize ដែលបច្ចុប្បន្នត្រូវឃុំខ្លួននៅពន្ធនាគារ សម្រាប់ជនឧក្រិដ្ឋនៅ Bangui សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល។ ដើមបណ្តឹងបានអះអាងថា ប្អូនប្រុសរបស់គាត់ គឺជាជនរងគ្រោះម្នាក់ ដោយការរំលោភសិទ្ធិមនុស្សរបស់អាជ្ញាធរ នៃសាធារណរដ្ឋអាហ្វ្រិកកណ្តាល។ ប៉ុន្តែគាត់មិនបានលើកឡើងពីមាត្រាណាមួយ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ។

## *អង្គហេតុ ដែលដាក់មកដោយដើមបណ្តឹង*

**២.១** ដើមបណ្តឹង បានអះអាងថា ប្អូនប្រុសរបស់គាត់ គឺជាមន្ត្រីយោធាជាន់ខ្ពស់ម្នាក់ នៃកងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋអាហ្វ្រិកកណ្តាល។ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៨២ ប្អូនប្រុសរបស់គាត់ បានផ្តើមធ្វើរដ្ឋប្រហារ (coup d'etat) មួយ។ បន្ទាប់ពីបរាជ័យ ប្អូនប្រុសរបស់គាត់ក៏បានភៀសខ្លួនទៅ Benin។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៩ ប្អូនប្រុសរបស់ដើមបណ្តឹងត្រូវបានចាប់ខ្លួននៅសណ្ឋាគារមួយក្នុងទីក្រុង Cotonou, Benin ជាមួយនឹងពលរដ្ឋសាធារណរដ្ឋអាហ្វ្រិកកណ្តាល ១១នាក់ ផ្សេងទៀត។ ពួកគេទាំងអស់ត្រូវបានសន្និដ្ឋានថា ជាសមាជិកនៃអ្នកនយោបាយប្រឆាំងឈ្មោះ ចលនាសេរីភាពជាតិអាហ្វ្រិកកណ្តាល។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៨៩ លោក Bozize និងសកម្មជនប្រឆាំងដទៃទៀត ត្រូវបានធ្វើមាតុភូមិនិវត្តទាំងបង្ខំ ដោយត្រូវគេ

ចោទថា បានជួយដល់កងកុម្ម៉ង់ដូយោធាសាធារណរដ្ឋអាហ្វ្រិកកណ្តាល ដែល នាំឲ្យមានប្រតិបត្តិការក្នុងប្រទេស Benin។ "ការធ្វើបត្យាប័ន"នេះ ត្រូវបានគេ និយាយថា ធ្វើឡើងដោយការចរចារវាងរដ្ឋាភិបាល Benin និងរដ្ឋាភិបាល សាធារណរដ្ឋអាហ្វ្រិកកណ្តាល។ ការធ្វើមាតុភូមិនិវត្តន៍ទាំងបង្ខំបានធ្វើឡើងដោយ គ្មានសំណើសុំធ្វើបត្យាប័នចេញដោយរដ្ឋាភិបាលអាហ្វ្រិកកណ្តាលនោះទេ។

**២.២** តាមរយៈការវិលត្រឡប់ទៅ Bangui វិញ លោក Bozize ត្រូវដាក់ នៅពន្ធនាគារ Camp Roux ជាទីកន្លែង ដែលគាត់បានចោទថា ត្រូវទទួលរង នូវការធ្វើបាបនិងការវាយដំយ៉ាងធ្ងន់ធ្ងរ។ ដើមបណ្តឹងអះអាងថា ប្អូនប្រុស របស់គាត់ មិនត្រូវបានអនុញ្ញាតឲ្យមានមេធាវីទៅតាមការជ្រើសរើសរបស់ខ្លួន និងមិនបានជួបសមាជិកគ្រួសាររបស់គាត់ផងដែរ។ សូម្បីតែគ្រូពេទ្យក៏មិនត្រូវ បានអនុញ្ញាតឲ្យមកពិនិត្យដើម្បីផ្តល់នូវការថែទាំមូលដ្ឋានដែរ។ លើសពីនេះ ទៅទៀត លក្ខខណ្ឌអនាម័យនៅក្នុងគុក ត្រូវបានគេនិយាយថា វេទនា ហើយ អាហារវិញ មានសាច់រលួយលាយជាមួយនឹងខ្សាច់។ ហេតុនេះហើយ បានជា ទម្ងន់របស់លោក Bozize បានចុះមកនៅត្រឹម៤០គីឡូ នៅក្នុងរដូវក្តៅឆ្នាំ១៩៩០។

**២.៣** នៅរាត្រីថ្ងៃទី១០ និងទី១១ ខែកក្កដា ឆ្នាំ១៩៩០ អាជ្ញាធរពន្ធនាគារ Camp Roux រាយការណ៍ថា មានការខកខានក្នុងការត្រួតពិនិត្យមើលនៅ ផ្នែកមួយនៃទីក្រុង ដែលជាទីកន្លែងពន្ធនាគារស្ថិតនៅ។ នេះជាការអះអាង ចង់លើកឡើងថា លោក Bozize ប៉ុនប៉ងក្នុងការរត់គេចខ្លួន។ តាមរយៈ សកម្មភាពនេះ ត្រូវបានគេនិយាយថា វាជារឿងទូទៅ និងជាលទ្ធផលមិន អាចជៀសរួចសម្រាប់ការស្លាប់របស់អ្នកចង់រត់គេចខ្លួន។ លោក Bozize មិន បានចាកចេញពីពន្ធនាគារទេ។ ដើមបណ្តឹងអះអាងថា ក្នុងយប់នោះប្អូនប្រុស របស់គាត់ត្រូវបានគេវាយដំយ៉ាងឃោរឃៅអស់ជាច្រើនម៉ោង និងរងរបួសយ៉ាង

ធ្ងន់ធ្ងរ។ ការបកស្រាយពីព្រឹត្តិការណ៍នេះ ត្រូវបានបញ្ជាក់ដោយមេធាវីរបស់លោក Bozize គឺលោក Maitre Thiangaye ជាអ្នកដែលអាចទៅជួបនឹងកូនក្តីរបស់ខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩០ និងជាអ្នកដែលបានធ្វើការកត់សម្គាល់ពីស្លាកស្នាម នៃការវាយដំជាច្រើននិងបានពិនិត្យឃើញថាលោក Bozize បានបាក់ឆ្អឹងជំនីចំនួនពីរ។ មេធាវីរូបនេះ ក៏បានរាយការណ៍ផងដែរថា លោក Bozize ត្រូវបានរឹតត្បិតក្នុងការនិយាយស្តី ហើយឯកសាររបស់គាត់ត្រូវបានគេរឹបអូស និងថា ឆ្មាំគុកបានអនុញ្ញាតឲ្យគាត់ចេញពីបន្ទប់ពីរដងប៉ុណ្ណោះក្នុងមួយសប្តាហ៍។ ដើមបណ្តឹងពោលទៀតថា ប្រព្រឹត្តកម្មនេះត្រូវបានដឹងឮដល់និងត្រូវបានលើកលែងទោសដោយលោកប្រធានាធិបតី Kolingba រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋ-មន្ត្រីក្រសួងមហាផ្ទៃ។

**២.៤** អាជ្ញាធរ នៃសាធារណរដ្ឋអាហ្វ្រិកកណ្តាល បានអះអាងយ៉ាងទទូចថាលោក Bozize បានព្យាយាមរត់គេចពីពន្ធនាគារពិតមែន និងថាគាត់ត្រូវទទួលរងរបួសក្នុងពេលរត់គេចនោះ។ ការលើកឡើងនេះ ត្រូវបានបដិសេធដោយដើមបណ្តឹង ដែលបានចង្អុលបង្ហាញពីលក្ខខណ្ឌនៃរាងកាយដ៏ទន់ខ្សោយរបស់ប្អូនប្រុសគាត់ក្នុងរដូវក្តៅឆ្នាំ១៩៩០ ព្រមទាំងបានលើកឡើងថា ប្អូនប្រុសរបស់គាត់ មិនអាចមានលទ្ធភាពឡើងរំលងជញ្ជាំងកម្ពស់បីម៉ែត្រនោះទេ។

**២.៥** ប្រពន្ធរបស់លោក Bozize ដែលកំពុងរស់នៅប្រទេសបារាំង បានដាក់សំណើទៅការិយាល័យនៃអាជ្ញាធរបារាំង។ តាមរយៈលិខិតចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩០ ប្រធានសភាជាតិបានជូនដំណឹងទៅលោកស្រីវិញថា ស្ថា-ប័នបរទេសបារាំងបានអះអាងថាលោក Bozize នៅមានជីវិតនៅឡើយនិងថាគាត់ត្រូវបានបញ្ជូនទៅពន្ធនាគារ Kassai នៅ Bangui។

២.៦ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់មធ្យោបាយក្នុងស្រុក ឲ្យអស់លទ្ធភាព ត្រូវបានគេលើកឡើងថា នីតិវិធីព្រហ្មទណ្ឌប្រឆាំងលោក Bozize ត្រូវបាន បើកធ្វើនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩១ គឺដើម្បីចំណេញពីអវត្តមានក្នុងរយៈ ដ៏ខ្លី នៃមេធាវីរបស់គាត់ ដែលត្រូវធ្វើដំណើរទៅបរទេស។ ទោះបីជាយ៉ាងណា សវនាការត្រូវបានផ្អាក ព្រោះ"មូលហេតុបច្ចេកទេស"។ ចាប់តាំងពីពេលនោះ សវនាការក៏ត្រូវបានផ្អាកជាច្រើនលើកផ្សេងទៀត។ អ្នកស្រី Bozize បាន ប្តឹងថា ក្នុងខែបន្ទាប់ពីការចាប់ខ្លួនប្តីគាត់ ត្រូវបានបដិសេធក្នុងការទទួលបាន មេធាវី។ ក្រោយមកគ្រួសារនេះ បានជួលមេធាវីម្នាក់មកការពារគាត់។ ប៉ុន្តែ មេធាវីនេះ ត្រូវបានបដិសេធក្នុងការផ្តល់អំណាចឲ្យជួបកូនក្តីរបស់ខ្លួន។ មេធាវី ក៏បានទទួលរងនូវការដាក់កំហិត នៃសេរីភាពក្នុងការធ្វើចលនារបស់គាត់ លើ ហេតុការណ៍របស់កូនក្តីដែរ ។

### *ការប្តឹង*

៣. ដើមបណ្តឹង បានប្តឹងមកថា ព្រឹត្តិការណ៍ ដែលបានរៀបរាប់ខាងលើ បង្កើតឲ្យមានការរំលោភសិទ្ធិរបស់លោក Bozize ក្រោមកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ថ្វីត្បិតតែដើមបណ្តឹង មិនបានលើកឡើង ឲ្យបានច្បាស់លាស់ថា បទប្បញ្ញត្តិណាមួយ នៃកតិកាសញ្ញាក៏ដោយ តែចេញពី បរិបទ នៃសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងការអះអាងនេះ មានជាប់ពាក់ព័ន្ធ នឹងមាត្រា៧, ៩, ១០, ១៤ និង១៩ នៃកតិកាសញ្ញានេះ។

### *សេចក្តីសម្រេច របស់គណៈកម្មាធិការ លើភាពអាចទទួលយកបាន*

៤.១ អំឡុងពេល នៃសម័យប្រជុំរបស់ខ្លួន ក្នុងខែកក្កដា ឆ្នាំ១៩៩២ គណៈ កម្មាធិការបានពិនិត្យពីភាពអាចទទួលយកបាននៃបណ្តឹងនេះ។ គណៈកម្មា-

ធិការ កត់សម្គាល់ឃើញថា ទោះបីជាមានការក្រើនរំឭកទៅដល់រដ្ឋភាគីចំនួនពីរលើក នៅក្នុងខែកក្កដានិងសីហា ឆ្នាំ១៩៩១ តែគ្មានព័ត៌មានឬការពិនិត្យទៅលើភាពអាចទទួលយកបាន នៃបណ្ដឹងនេះត្រូវបានទទួលពីរដ្ឋភាគីទេ។ នៅក្នុងស្ថានភាពជាច្រើនគណៈកម្មាធិការបានរកឃើញថា ខ្លួនមិនអាចប្រានចោលការពិនិត្យមើលក្រោមមាត្រា៥ កថាខណ្ឌទី២(ខ) នៃពិធីសារបន្ថែមបានទេ។

**៤.២** នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩២ គណៈកម្មាធិការ បានប្រកាសថា បណ្ដឹងនេះអាចទទួលយកបាន ពីព្រោះបណ្ដឹងនេះ បានបង្ហាញឲ្យឃើញពីបញ្ហាផ្សេងៗ នៅក្រោមមាត្រា៧ មាត្រា៩ មាត្រា១០ មាត្រា១៤ កថាខណ្ឌទី១ និងទី៣ ព្រមទាំងមាត្រា១៩ នៃកតិកាសញ្ញា។

*ការពិនិត្យទៅលើអង្គសេចក្ដី*

**៥.១** រដ្ឋភាគី មិនបានផ្ដល់ព័ត៌មានណាមួយ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ដើមបណ្ដឹងទេ។ ទោះបីជាមានការដាស់តឿនចំនួនពីរលើក ក្នុងខែមិថុនា ឆ្នាំ១៩៩៣ និងខែកុម្ភៈ ឆ្នាំ១៩៩៤ ។ គណៈកម្មាធិការ បានសម្ដែងនូវការសោកស្ដាយនិងការព្រួយបារម្ភជាខ្លាំង ដោយសារតែអវត្តមាននៃកិច្ចសហ-ប្រតិបត្តិការរបស់រដ្ឋភាគី ទាំងក្នុងដំណាក់កាល នៃភាពអាចទទួលយកបានរបស់បណ្ដឹងនេះនិងទាំងដំណាក់កាល នៃការចោទប្រកាន់របស់ដើមបណ្ដឹង។ មានការបញ្ជាក់យ៉ាងច្បាស់នៅក្នុងមាត្រា៤ កថាខណ្ឌទី២ នៃពិធីសារបន្ថែមនិងក្នុងវិធាន៩១ នៃវិធាននីតិវិធីរបស់គណៈកម្មាធិការដែលរដ្ឋភាគីនៃកតិកាសញ្ញាត្រូវតែស៊ើបអង្កេតឲ្យបានត្រឹមត្រូវរាល់ការចោទប្រកាន់ប្រឆាំងនឹងខ្លួនពីបទរំលោភកតិកាសញ្ញានេះ ហើយអាជ្ញាធរត្រូវផ្ដល់ព័ត៌មានដែលមានទៅ

គណៈកម្មាធិការ។ ពេលខ្លះ ទម្ងន់សមស្របត្រូវតែផ្តល់ទៅឲ្យបទចោទប្រកាន់របស់ដើមបណ្តឹងទៅ តាមទំហំដែលគេបានបញ្ជាក់ភ័ស្តុតាង។

**៥.២** គណៈកម្មាធិការ សម្រេចដាក់មូលដ្ឋានទស្សនៈរបស់ខ្លួនលើអង្គហេតុផ្សេងៗ ដែលរដ្ឋភាគីមិនបានជំទាស់។ លោក Francois Bozize ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៩ និងត្រូវនាំខ្លួនទៅជំរំទាហាន Roux, Banbui នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៨៩។ នៅទីនោះ *គាត់ត្រូវទទួលរងនូវការធ្វើបាប និងត្រូវឃុំខ្លួន ដោយមិនអនុញ្ញាតឲ្យជួបអ្នកណាទាំងអស់ រហូតដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩០ ពេលដែលមេធាវីរបស់គាត់អាចចូលទៅជួបគាត់បាន។ នៅរាត្រីថ្ងៃទី១០ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩០ គាត់ត្រូវបានគេវាយដំ និងត្រូវទទួលរងរបួសយ៉ាងធ្ងន់ធ្ងរ ដែលត្រូវបានបញ្ជាក់ដោយមេធាវីរបស់គាត់។ ជាងនេះទៅទៀត ខណៈដែលឃុំខ្លួននៅជំរំ Roux គាត់ត្រូវបានគេដាក់នៅក្រោមលក្ខខណ្ឌដែលមិនគោរពតម្លៃជាមនុស្សពីកំណើតទេ។ បន្ទាប់ពីការចាប់ខ្លួនរបស់គាត់ លោក Bozize មិនត្រូវបាននាំខ្លួនភ្លាមៗទៅជួបចៅក្រម ឬមន្ត្រី ដែលផ្តល់អំណាចដោយច្បាប់ក្នុងការអនុវត្តន៍អំណាចតុលាការទេ។ គាត់ត្រូវគេបដិសេធក្នុងការទទួលបានមេធាវី ហើយគាត់មិនមានឱកាសទទួលបានសេចក្តីសម្រេចមួយដោយតុលាការ ក្នុងពេលវេលាសមស្របមួយ ទៅលើភាពស្របច្បាប់ នៃការចាប់ខ្លួននិងការឃុំខ្លួនរបស់គាត់ទេ។* គណៈកម្មាធិការរកឃើញថាក្នុងករណីនេះ អ្វីដែលបានលើកឡើងខាងលើ ស្មើទៅនឹងការរំលោភដោយរដ្ឋភាគីលើមាត្រា៧, ៩, និងមាត្រា១០។

**៥.៣** *គណៈកម្មាធិការ កត់សម្គាល់ថា ទោះបីជាលោក Bozize មិនទាន់ត្រូវបានកាត់ទោសក៏ដោយ ក៏សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានរំលោភដែរ។ ជាពិសេសសិទ្ធិទទួលបានការជំនុំជម្រះក្នុង " រយៈពេលសម*

*ស្រប" មួយក្រោមមាត្រា១៤ កថាខណ្ឌទី៣(គ) មិនត្រូវបានគោរព ពីព្រោះ គាត់មិនត្រូវបានគេជំនុំជម្រះនៅដំណាក់កាលដំបូង បន្ទាប់ពីការឃុំខ្លួនអស់រយៈពេលជាងបួនឆ្នាំ ។*

**៥.៤** ចំពោះលទ្ធភាព ដែលអាចរំលោភមាត្រា១៩ នៃកតិកាសញ្ញាគណៈកម្មាធិការកត់សម្គាល់ឃើញថាការអះអាងនេះមិនមានភស្តុតាងបញ្ជាក់ទេ។ ហេតុនេះ តុលាការមិនបានរកឃើញថា មានការរំលោភមាត្រានេះទេ។

**៦.** គណៈកម្មាធិការសិទ្ធិមនុស្ស បានពិនិត្យមើលក្រោមមាត្រា៥ កថាខណ្ឌទី៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយសម្រេចថា តាមរយៈអង្គហេតុបានបង្ហាញឲ្យឃើញនូវការរំលោភមាត្រា៧ មាត្រា៩ មាត្រា១០ និងមាត្រា១៤ កថាខណ្ឌទី៣(គ) នៃកតិកាសញ្ញា។

**៧.** *គណៈកម្មាធិការ យល់ឃើញថា លោក Francois Bozize ក្រោមមាត្រា២ កថាខណ្ឌទី៣(ក)នៃកតិកាសញ្ញា ត្រូវទទួលបានដំណោះស្រាយប្រកប ដោយប្រសិទ្ធភាព រួមទាំងការដោះលែង និងសំណងសមរម្យ ចំពោះអំពើដែលគាត់បានទទួលរង។ រដ្ឋភាគី គួរតែស៊ើបអង្កេតលើព្រឹត្តិការណ៍ ដែលបានប្តឹងមក និងនាំអ្នកទាំងឡាយណា ដែលត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តលើដើមបណ្តឹង ទៅតុលាការ។ គណៈកម្មាធិការបានបន្តទៀតថា រដ្ឋភាគីស្ថិតក្រោមកាតព្វកិច្ចក្នុងការចាត់វិធានការឲ្យមានប្រសិទ្ធភាព ដើម្បីធានាថា ការរំលោភបំពានប្រហាក់ប្រហែល គ្នានេះ នឹងមិនកើតឡើងទៀតទេក្នុងពេលអនាគត។*

**៨.** គណៈកម្មាធិការសង្ឃឹមថា នឹងទទួលបានព័ត៌មានភ្លាមៗ ស្តីពីវិធានការពាក់ព័ន្ធ ដែលធ្វើឡើងដោយរដ្ឋភាគី ជាការគោរពទៅតាមយោបល់របស់គណៈកម្មាធិការ ។